# ព្រះរាជក្រម

នស/រកម/១១១៧/០៧៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល
លេខ [illegible]
ថ្ងៃទី២៤/១១ ឆ្នាំ២០១៧ ម៉ោង១០:០០
បញ្ជូនទៅ [illegible]

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣៧ មាត្រា ៣៨ មាត្រា ១០៩ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម /០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា ៣៧ មាត្រា ៣៨ មាត្រា ១០៩ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្មវិញ្ញាបនបត្រម៉ូដែល មានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/ ០១០៣/០០៥

## ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា ៣៧ មាត្រា ៣៨ មាត្រា ១០៩ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៣ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ៣៧.-ថ្មី**

យោងតាមមាត្រា ៣៦ នៃច្បាប់នេះ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យបន្ថែមនូវចំណុចដូចខាងក្រោម ៖

១- លទ្ធផលនៃរបាយការណ៍ស្រាវជ្រាវរបស់អន្តរជាតិ និងលទ្ធផលរបាយការណ៍ពិនិត្យជំហានដំបូងរបស់អន្តរជាតិ ដែលធ្វើឡើងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មរបស់សំណុំលិខិតស្នើសុំ ។

២- របាយការណ៍ស្រាវជ្រាវនិងរបាយការណ៍ពិនិត្យ ដែលបានចែងនៅក្នុងចំណុច **ក** របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ ឬសេចក្តីសម្រេចចុងក្រោយដែលបានចែងនៅក្នុងចំណុច **គ** របស់វាក្យខណ្ឌទី ១ នៃមាត្រា ៣១ នៃច្បាប់នេះស្តីពីការបដិសេធផ្តល់ប្រកាសនីយបត្រតក្កកម្ម ចំពោះសំណុំលិខិតស្នើសុំនៅឯបរទេស ។

៣- របាយការណ៍ស្រាវជ្រាវនិងរបាយការណ៍ពិនិត្យដែលបានធ្វើឡើងដោយស្ថាប័នស្រាវជ្រាវនិងពិនិត្យនៅក្រៅប្រទេស តាមសំណើរបស់មន្ត្រីកាន់កាប់បញ្ជី ។

៤- មន្ត្រីកាន់កាប់បញ្ជីត្រូវចុះផ្សាយអំពីសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម លទ្ធផលរបាយការណ៍ស្រាវជ្រាវ និងរបាយការណ៍ពិនិត្យសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ។

**មាត្រា ៣៨.-ថ្មី**

ការផ្តល់ប្រកាសនីយបត្រតក្កកម្មត្រូវអនុវត្តដូចខាងក្រោម ៖

១- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់នេះត្រូវបានបំពេញរួច មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការផ្តល់ប្រកាសនីយបត្រតក្កកម្មជូនអ្នកដាក់ពាក្យសុំ ។ បើមិនដូច្នោះទេមន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំ និងជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីសេចក្តីសម្រេចនេះ ។

២- ក្នុងករណីពិនិត្យឃើញថា ប្រកាសនីយបត្រតក្កកម្មដែលផ្ដល់នៅបរទេសមានប្រយោជន៍ដល់កម្ពុជា រដ្ឋមន្ត្រីអាចចេញសេចក្ដីសម្រេចទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មនៅកម្ពុជាបាន ។ រដ្ឋមន្ត្រីត្រូវចេញបទបញ្ជាចាំបាច់ណែនាំលម្អិត អំពីការអនុវត្តចំពោះការទទួលស្គាល់ប្រកាស នីយបត្រតក្កកម្មនេះ ។

## មាត្រា ១០៩._ថ្មី

ការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

១- ការចុះបញ្ជីគំនូរឧស្សាហកម្មមានសុពលភាពប្រាំ (៥) ឆ្នាំ ចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំ ។ ការចុះបញ្ជីអាចធ្វើសាឡើងវិញបានចំនួនពីរ (២) ដងជាប់ៗគ្នា ដែលម្ដងៗមានសុពលភាពប្រាំ (៥) ឆ្នាំ ដោយម្ចាស់គំនូរឧស្សាហកម្មត្រូវបង់កម្រៃបន្តសុពលភាពតាមការកំណត់ ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។ ការយឺតយ៉ាវក្នុងការបង់កម្រៃបន្តសុពលភាពនេះ ត្រូវអនុញ្ញាតយ៉ាងយូរត្រឹមប្រាំមួយ (៦) ខែ ដោយត្រូវមានការបង់កម្រៃបន្ថែមលើការយឺតយ៉ាវនោះទៅតាមការកំណត់ ដូចមានចែងក្នុងមាត្រា ១៣០ នៃច្បាប់នេះ ។

២- សំណុំលិខិតស្នើសុំចុះបញ្ជីក្រោមសន្ធិសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៩៩ នៃកិច្ចព្រមព្រៀងទីក្រុងហេច ទាក់ទងនឹងការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិ ដែលព្រះរាជាណាចក្រកម្ពុជាបានជ្រើសរើស ត្រូវបានចាត់ទុកថា ជាសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីនៅក្រោមច្បាប់នេះ ដោយមានកាលបរិច្ឆេទសុំចុះបញ្ជីដូចគ្នាទៅនឹងកាលបរិច្ឆេទអន្តរជាតិ ដូចមានចែងនៅក្នុងសន្ធិសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៩៩ នៃកិច្ចព្រមព្រៀងទីក្រុងហេច ទាក់ទងនឹងការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិ ។ រដ្ឋមន្ត្រីត្រូវចេញបទបញ្ជាចាំបាច់ណែនាំលម្អិតអំពីការអនុវត្តការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិក្រោមសន្ធិសញ្ញានេះ ។

៣- ក្នុងករណីពិនិត្យឃើញថា គំនូរឧស្សាហកម្មដែលចុះបញ្ជីនៅបរទេសមានប្រយោជន៍ដល់កម្ពុជា រដ្ឋមន្ត្រីអាចចេញសេចក្ដីសម្រេចទទួលស្គាល់គំនូរឧស្សាហកម្មនេះនៅកម្ពុជាបាន ។ រដ្ឋមន្ត្រីត្រូវចេញបទបញ្ជាចាំបាច់ណែនាំលម្អិតអំពីការអនុវត្តការទទួលស្គាល់គំនូរឧស្សាហកម្មនេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

**មាត្រា ១៣៦.-ថ្មី**

ផលិតផលឱសថ ដូចមានចែងក្នុងមាត្រា ៤ នៃច្បាប់នេះ មិនត្រូវបានការពារដោយប្រកាសនីយបត្រតក្កកម្មរហូតដល់ផុតរយៈពេលអនុគ្រោះ ដែលត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញារបស់អង្គការពាណិជ្ជកម្មពិភពលោក អំពីការពន្យាររយៈពេល អនុគ្រោះ អនុលោមតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា សម្រាប់សមាជិកដែលជាប្រទេសអភិវឌ្ឍតិចតួច ក្នុងកាតព្វកិច្ចដាក់លាក់ចំពោះផលិតផលឱសថ ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**

**នរោត្តម សីហមុនី**

នស/រកម.១១១៧.០២៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ហត្ថលេខា**

**ចម ប្រសិទ្ធ**

លេខ:១០៦៤ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**